**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ចំណុះអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា ១៣ និងមាត្រា ៣០ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងការកែសម្រួលមាត្រា ១១ថ្មី នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

## សម្រេច

**មាត្រា ១.**

ត្រូវបានបង្កើតនាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ចំណុះអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

**មាត្រា ២.**

នាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ មានភារកិច្ចដូចតទៅ ÷

- រៀបចំបង្កើត និងអភិវឌ្ឍស្តង់ដាគុណភាពអប្បបរមា សម្រាប់វាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ
- រៀបចំបង្កើត និងអភិវឌ្ឍគោលការណ៍ណែនាំសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងសម្រាប់មន្ត្រីវាយតម្លៃ
- រៀបចំបង្កើតយន្តការវាយតម្លៃថ្នាក់ក្រោយបរិញ្ញាបត្រ
- រៀបចំការចុះវាយតម្លៃ និងពិនិត្យឡើងវិញលើដំណើរការទទួលស្គាល់គុណភាពអប់រំនៃការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ
- លើកសំណើចាត់តាំងក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំ សម្រាប់ដំណើរការចុះវាយតម្លៃ ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំលើការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ
- លើកសំណើចាត់តាំងមន្ត្រីបច្ចេកទេស ដើម្បីចុះពិនិត្យឡើងវិញលើដំណើរការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ
- លើកសំណើជ្រើសរើសមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ
- លើកសំណើបណ្តុះបណ្តាលមន្ត្រីវាយតម្លៃ ដើម្បីបង្កើនសមត្ថភាពវិជ្ជាជីវៈ
- សម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃការងាររបស់មន្ត្រីវាយតម្លៃ
- ពិនិត្យរបាយការណ៍របស់ក្រុមមន្ត្រីវាយតម្លៃ
- ផ្តល់ការពិគ្រោះយោបល់ដល់គ្រឹះស្ថានឧត្តមសិក្សា ពាក់ព័ន្ធនឹងដំណើរការទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ
- ពិនិត្យ និងលើកសំណើសុំផ្តល់ការទទួលស្គាល់គុណភាពអប់រំលើការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ តាមនីតិវិធី
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានតាមការកំណត់
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គលេខាធិការប្រគល់ជូន។

នាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ៣.**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៤.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៥.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*